**ព្រះរាជាណាចក្រកម្ពុជា**

**ជាតិ សាសនា ព្រះមហាក្សត្រ**

**រាជរដ្ឋាភិបាលកម្ពុជា**

លេខៈ ៧៥ អនក្រ.បក

# អនុក្រឹត្យ

## ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅ
## របស់ក្រសួងអភិវឌ្ឍន៍ជនបទ

## រាជរដ្ឋាភិបាលកម្ពុជា

- បានឃើញរដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា ឆ្នាំ១៩៩៣
- បានឃើញព្រះរាជក្រឹត្យចុះថ្ងៃទី ២៤ ខែកញ្ញា ឆ្នាំ១៩៩៣ ស្តីពីការតែងតាំងនាយករដ្ឋមន្ត្រីទី១ និងនាយករដ្ឋមន្ត្រីទី២
- បានឃើញព្រះរាជក្រឹត្យចុះថ្ងៃទី ០១ ខែវិច្ឆិកា ឆ្នាំ១៩៩៣ ស្តីពីការតែងតាំងរាជរដ្ឋាភិបាលកម្ពុជា
- បានឃើញព្រះរាជក្រមលេខ ០២/នស/៩៤ ចុះថ្ងៃទី ២០ ខែកក្កដា ឆ្នាំ១៩៩៤ ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅរបស់គណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/១០៩៤/៨៣ ចុះថ្ងៃទី ២៤ ខែតុលា ឆ្នាំ១៩៩៤ និងព្រះរាជក្រឹត្យលេខ នស/រកត/១០៩៤/៩០ ចុះថ្ងៃទី ៣១ ខែតុលា ឆ្នាំ១៩៩៤ ស្តីពីការកែសំរួលសមាសភាពរាជរដ្ឋាភិបាលកម្ពុជា
- បានឃើញព្រះរាជក្រមលេខ នស/រកម/០១៩៦/១២ ចុះថ្ងៃទី ២៤ ខែមករា ឆ្នាំ១៩៩៦ ស្តីពីការបង្កើតក្រសួងអភិវឌ្ឍន៍ជនបទ
- បានឃើញព្រះរាជក្រឹត្យលេខ ជស/រកត/០៨៩៧/១៤៧ ចុះថ្ងៃទី ៧ ខែសីហា ឆ្នាំ១៩៩៧ ស្តីពីការកែសំរួលសមាសភាពរាជរដ្ឋាភិបាលកម្ពុជា
- បានឃើញអនុក្រឹត្យលេខ ២០ អនក្រ/បក ចុះថ្ងៃទី ៣០ ខែមេសា ឆ្នាំ១៩៩៦ ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅរបស់ក្រសួង និងរដ្ឋលេខាធិការដ្ឋាន
- តាមសំណើរបស់រដ្ឋមន្ត្រីក្រសួងអភិវឌ្ឍន៍ជនបទ
- តាមការឯកភាពរបស់គណៈរដ្ឋមន្ត្រី នាសម័យប្រជុំថ្ងៃទី ១៦ ខែតុលា ឆ្នាំ១៩៩៧

## សំរេច

## ជំពូក ១

## បទបញ្ញត្តិទូទៅ

**មាត្រា ១:** អនុក្រឹត្យនេះរៀបចំបណ្តាអង្គភាពនៃក្រសួងអភិវឌ្ឍន៍ជនបទ និងកំណត់បេសកកម្មរបស់ក្រសួង និងមុខការនៃអគ្គនាយកដ្ឋាន និងនាយកដ្ឋាននានា ។

## ជំពូក ២

## បេសកកម្ម និងរចនាសម្ព័ន្ធ

**មាត្រា ២:** ក្រសួងអភិវឌ្ឍន៍ជនបទ ត្រូវបានរាជរដ្ឋាភិបាលកម្ពុជាប្រគល់បេសកកម្មឱ្យដឹកនាំ និងគ្រប់គ្រងវិស័យអភិវឌ្ឍន៍ជនបទនៃព្រះរាជាណាចក្រកម្ពុជា ។

**មាត្រា ៣:** ក្រសួងអភិវឌ្ឍន៍ជនបទមានមុខងារ និងភារកិច្ចដូចតទៅ:

- កំណត់នយោបាយ និងយុទ្ធសាស្ត្រនៃការអភិវឌ្ឍន៍ជនបទ ស្របតាមកម្មវិធីនយោបាយរបស់រាជរដ្ឋាភិបាល ។
- លើកទិសដៅ ផែនការរយៈពេលខ្លី មធ្យម វែង លើការងារអភិវឌ្ឍន៍ជនបទដើម្បីកែលំអស្ថានភាពសេដ្ឋកិច្ច សង្គមកិច្ច និងវប្បធម៌របស់ប្រជារាស្ត្រជនបទឱ្យកាន់តែល្អប្រសើរឡើង កាត់បន្ថយជាបណ្តើរៗនូវភាពក្រីក្រ និងភាពខុសគ្នារវាងអ្នកជនបទ និងអ្នកទីក្រុង ។
- ចូលរួមក្នុងការកសាង និងអភិវឌ្ឍន៍ប្រទេសជាតិក្នុងវិស័យអភិវឌ្ឍន៍ជនបទ ដោយគិតសកម្មភាពការងារត្រឹមថ្នាក់គ្រួសារ ភូមិ និងឃុំ ក្នុងព្រះរាជាណាចក្រកម្ពុជា ។
- សិក្សាស្រាវជ្រាវ ប្រមូលផ្តុំ និងគ្រប់គ្រងទិន្នន័យ ពត៌មាន ស្ថិតិ អំពីស្ថានភាពសេដ្ឋកិច្ច សង្គមកិច្ច និងវប្បធម៌ នៅតំបន់ជនបទនៃព្រះរាជាណាចក្រកម្ពុជា ដោយសហការជាមួយស្ថាប័នពាក់ព័ន្ធ ។
- អភិវឌ្ឍធនធានមនុស្ស តាមរយៈការបណ្តុះបណ្តាលបច្ចេកទេសជំនាញ និងចំណេះដឹងដល់មន្ត្រី បុគ្គលិករាជការរបស់ក្រសួង ។
- រៀបចំបើកមជ្ឈមណ្ឌលបណ្តុះបណ្តាលបច្ចេកទេស និងវិជ្ជាជីវៈ ថ្នាក់ភូមិភាគ ដល់ប្រជារាស្ត្រជនបទតាមការចាំបាច់ និងតាមលទ្ធភាពជាក់ស្តែង ។

- អប់រំ ផ្សព្វផ្សាយ ដើម្បីលើកកំពស់ផលិតភាព និងប្រាក់ចំណូលប្រចាំគ្រួសាររបស់ប្រជាពលរដ្ឋ ដោយផ្អែកលើការស្រាវជ្រាវបច្ចេកទេសជំនាញអភិវឌ្ឍន៍ជនបទ ។
- ធ្វើទំនាក់ទំនង សំរបសំរួល និងសហប្រតិបត្តិការជាមួយបរទេស អង្គការអន្តរជាតិ អង្គការមិនមែនរដ្ឋាភិបាល ស្ថាប័នរដ្ឋ អាជ្ញាធរគ្រប់ជាន់ថ្នាក់ និងផ្នែកឯកជនដែលមានការពាក់ព័ន្ធ ព្រមទាំងប្រជារាស្ត្រមូលដ្ឋាន ដើម្បីធ្វើការអភិវឌ្ឍន៍ជនបទ ប្រកបដោយភាពស្ថិតស្ថេរយូរអង្វែង ។
- គ្រប់គ្រង ដឹកនាំ និងទទួលខុសត្រូវ ក្នុងការអនុវត្តកម្មវិធីអភិវឌ្ឍន៍ជនបទចំរុះ ថ្នាក់គ្រួសារ ភូមិ ឃុំ ដែលរួមមានផ្លូវលំជនបទ ផ្គត់ផ្គង់ទឹកជនបទ ថែទាំសុខភាពបឋម អភិវឌ្ឍសហគមន៍ និងអភិវឌ្ឍសេដ្ឋកិច្ចជនបទ ដោយសហការជាមួយស្ថាប័នពាក់ព័ន្ធ ។
- ជំរុញការរៀបចំ និងពង្រឹងរចនាសម្ព័ន្ធអភិវឌ្ឍន៍ជនបទគ្រប់ជាន់ថ្នាក់ ជាពិសេសគណៈកម្មការអភិវឌ្ឍន៍ជនបទនៅមូលដ្ឋាន ។

**មាត្រា ៤:** ក្រសួងអភិវឌ្ឍន៍ជនបទមានរចនាសម្ព័ន្ធដូចតទៅ:
- អគ្គាធិការដ្ឋាន
- អគ្គនាយកដ្ឋានរដ្ឋបាល និងហិរញ្ញវត្ថុ
- អគ្គនាយកដ្ឋានបច្ចេកទេស
- ខុទ្ទកាល័យរដ្ឋមន្ត្រី
- អង្គភាពមូលដ្ឋាន ។

អង្គការលេខរបស់ក្រសួងអភិវឌ្ឍន៍ជនបទ ជាឧបសម្ព័ន្ធរបស់អនុក្រឹត្យនេះ ។

## ជំពូក ៣
## អគ្គាធិការដ្ឋាន

**មាត្រា ៥:** អគ្គាធិការដ្ឋានរបស់ក្រសួងអភិវឌ្ឍន៍ជនបទទទួលបន្ទុក:
- ធ្វើអធិការកិច្ចជាប្រចាំទៅលើគ្រប់អង្គភាព ក្រោមឱវាទក្រសួងអភិវឌ្ឍន៍ជនបទ ។
- ធ្វើរបាយការណ៍ជូនរដ្ឋមន្ត្រី ពីការប្រព្រឹត្តទៅរបស់អង្គភាព ដែលបានធ្វើអធិការកិច្ចរួចហើយ និងពីមធ្យោបាយកែលំអការប្រព្រឹត្តទៅ របស់អង្គភាពទាំងនោះ ។
- ប្រតិបត្តិភារកិច្ចតាមការដែលរដ្ឋមន្ត្រីបានប្រគល់ទំនុកចិត្ត ។

អគ្គាធិការដ្ឋានដឹកនាំដោយអគ្គាធិការមួយរូប និងអមដោយអគ្គាធិការរងជាជំនួយការ ។

# ជំពូក ៤

## អគ្គនាយកដ្ឋានរដ្ឋបាល និងហិរញ្ញវត្ថុ

**មាត្រា ៦:** អគ្គនាយកដ្ឋានរដ្ឋបាល និងហិរញ្ញវត្ថុ ទទួលបន្ទុកធ្វើទំនាក់ទំនង សំរបសំរួល និងគ្រប់គ្រងការងាររដ្ឋបាល បុគ្គលិក សម្ភារៈ បរិក្ខារ គណនេយ្យ ហិរញ្ញកិច្ច ផែនការ ស្ថិតិ តាមដាន និងវាយតម្លៃ សហប្រតិបត្តិការជាតិ និងអន្តរជាតិ ព្រមទាំងការងារបណ្តុះបណ្តាល ស្រាវជ្រាវ និងផ្សព្វផ្សាយ ។ អគ្គនាយកដ្ឋានដឹកនាំដោយអគ្គនាយកមួយរូប និងអាចអមដោយអគ្គនាយករង ជាជំនួយការតាមការចាំបាច់ ។ អគ្គនាយកដ្ឋាននេះមាននាយកដ្ឋានចំណុះចំនួន ៤:

- នាយកដ្ឋានរដ្ឋបាល និងបុគ្គលិក
- នាយកដ្ឋានផ្គត់ផ្គង់ និងហិរញ្ញវត្ថុ
- នាយកដ្ឋានផែនការ និងទំនាក់ទំនងសាធារណៈ
- នាយកដ្ឋានបណ្តុះបណ្តាល និងស្រាវជ្រាវ ។

**មាត្រា ៧:** នាយកដ្ឋានរដ្ឋបាល និងបុគ្គលិកទទួលបន្ទុកៈ

- សំរបសំរួលសកម្មភាពគ្រប់ផ្នែក របស់ក្រសួងនៅថ្នាក់កណ្តាល និងរវាងថ្នាក់កណ្តាល និងអង្គភាពមូលដ្ឋានក្រោមឱវាទក្រសួង ។
- រៀបចំរាល់លិខិតរដ្ឋបាល សំរាប់ការគ្រប់គ្រងអាជីព ។
- គ្រប់គ្រង និងចរាចរឯកសាររដ្ឋបាលផ្សេងៗរបស់ក្រសួង ។
- ធានាប្រសិទ្ធភាព សុវត្ថិភាពរដ្ឋបាល ការពារសន្តិសុខ ថែរក្សាសណ្តាប់ធ្នាប់ និងគ្រប់គ្រងការងារសង្គមរបស់ក្រសួង ។
- គ្រប់គ្រងផ្នែករដ្ឋបាល មន្ត្រីរាជការ និងភ្នាក់ងាររាជការរបស់ក្រសួង ដោយទំនាក់ទំនងនឹងរដ្ឋលេខាធិការដ្ឋានមុខងារសាធារណៈ ។
- រៀបចំស្ថិតិលើការគ្រប់គ្រងបុគ្គលិក និងតារាងពតិមានប្រតិបត្តិ ។
- ធ្វើកម្មវិធីពីតំណែងឯកទេស និងធនធានមនុស្សរបស់ក្រសួង ដោយទំនាក់ទំនងនឹងរដ្ឋលេខាធិការដ្ឋានមុខងារសាធារណៈ ។
- រៀបចំនយោបាយបណ្តុះបណ្តាលដំបូង និងបន្ត ដោយទំនាក់ទំនងនឹងរដ្ឋលេខាធិការដ្ឋានមុខងារសាធារណៈ និងអនុវត្តនយោបាយនោះ ។

- លើកសំណើបង្កើត-រំសាយអង្គភាពនានា រៀបចំតួនាទីភារកិច្ច កែសំរួលរចនាសម្ព័ន្ធ តាមស្ថានភាពជាក់ស្តែង តាមការប្រគល់ភារកិច្ចរបស់ប្រធានស្ថាប័ន ។
- គ្រប់គ្រងយានយន្តរបស់រដ្ឋ ដែលបំរើការងាររដ្ឋបាលនៅក្នុងក្រសួង ។

**មាត្រា ៨:** នាយកដ្ឋានផ្គត់ផ្គង់ និងហិរញ្ញវត្ថុទទួលបន្ទុកៈ

- ប្រមូលផ្តុំតម្រូវការ លើកគំរោងថវិកាក្រសួង ធ្វើកម្មវិធីចំណាយ និងតាមដានរំលឹកពីការប្រតិបត្តិ ។
- សំរបសំរួលជំពូកថវិកា និងរាល់ចំណាយរបស់ក្រសួង ។
- គ្រប់គ្រងចលនទ្រព្យ អចលនទ្រព្យ សន្និធិសម្ភារៈ និងធ្វើបញ្ជីសារពើភ័ណ្ឌ ។
- ធ្វើកម្មវិធីចំណាយ និងបែងចែកប្រេងឥន្ធនៈ គ្រឿងបន្លាស់ សំរាប់យានយន្តរបស់រដ្ឋដែលប្រគល់ជូនក្រសួង ។
- គ្រប់គ្រងការជួសជុលសម្ភារៈ និងបរិក្ខារ របស់ក្រសួង ។
- ទទួល និងបែងចែកបរិក្ខារ ជូនដល់បណ្តាអង្គភាពនានាក្រោមឱវាទក្រសួង ។
- កាន់បញ្ជីជាប្រចាំនូវសលាកប័ត្រ និងគណនេយ្យរូបធាតុ ។
- គ្រប់គ្រងពត៌មានវិទ្យា សកម្មភាពខាងហិរញ្ញវត្ថុ និងបន្ទុកគណនី ។
- ត្រួតពិនិត្យបច្ចេកទេស នៃការប្រតិបត្តិលទ្ធកម្មសាធារណៈ ។
- គ្រប់គ្រងបន្ទុកគណនី របស់ការអនុវត្តលទ្ធកម្មសាធារណៈ ។
- តាមដានរំលឹកការគ្រប់គ្រងគណនីពិសេស ។
- ប្រមូលចំណូលឱ្យបានសមស្រប តាមច្បាប់ហិរញ្ញវត្ថុដែលបានកំណត់ ។

**មាត្រា ៩:** នាយកដ្ឋានផែនការ និងទំនាក់ទំនងសាធារណៈទទួលបន្ទុកៈ

- រៀបចំ ចងក្រង គ្រប់គ្រង ប្រព័ន្ធទិន្នន័យ ស្ថិតិរបស់ក្រសួង និងលើកផែនការអភិវឌ្ឍន៍ជនបទរយៈពេលខ្លី មធ្យម និងយូរអង្វែង លើគ្រប់ផ្នែកទាំងអស់ ។
- ធ្វើកម្មវិធីសហប្រតិបត្តិការ ក្នុង និងក្រៅ ប្រទេស. លើវិស័យអភិវឌ្ឍន៍ជនបទ ។
- សំរបសំរួលជំនួយពីបរទេស និងត្រួតពិនិត្យការអនុវត្ត ។
- រៀបចំឯកសារកិច្ចព្រមព្រៀង ឬពិធីសារនៃកិច្ចសហប្រតិបត្តិការ រវាងក្រសួងអភិវឌ្ឍន៍ជនបទ ជាមួយភ្នាក់ងារសហប្រជាជាតិ អង្គការអន្តរជាតិ ព្រមទាំងអង្គការមិនមែនរដ្ឋាភិបាលជាតិ និងអន្តរជាតិ ។

- ណែនាំ ជំរុញ តាមដាន និងវាយតម្លៃលើការអនុវត្ត និងលទ្ធផលសំរេចបានលើផែនការដែលបានដាក់ចុះ ។
- ចូលរួមផ្តល់យោបល់ និងតាមដាន វាយតម្លៃ លើការប្រើប្រាស់ទុនវិនិយោគក្នុងការអនុវត្តផែនការរដ្ឋ ។
- បូកសរុបរបាយការណ៍បច្ចេកទេស សេដ្ឋកិច្ច និងសង្គមកិច្ច គ្រប់ផ្នែកនៃវិស័យអភិវឌ្ឍន៍ជនបទ ។
- រៀបចំ និងបោះពុម្ពផ្សាយនូវព្រឹត្តិប័ត្រពត៌មានស្តីពីស្ថិតិ និងសកម្មភាពការងារសំរេចបាននៃគំរោងការងារអភិវឌ្ឍន៍ជនបទ ។

**មាត្រា ១០:** នាយកដ្ឋានបណ្តុះបណ្តាល និងស្រាវជ្រាវទទួលបន្ទុក:

- វាយតម្លៃតម្រូវការក្នុងការបណ្តុះបណ្តាល ។
- រៀបចំ លើកផែនការបណ្តុះបណ្តាល សិក្ខាសាលា ស្រាវជ្រាវ និងផ្សព្វផ្សាយរយៈពេលខ្លី មធ្យម និងយូរអង្វែង ។
- រៀបចំកម្មវិធីសំរាប់បណ្តុះបណ្តាលក្របខ័ណ្ឌ និងវិជ្ជាជីវៈ ទៅតាមតម្រូវការជាក់ស្តែងនៃការងារហ្វឹកហ្វឺន ។
- បណ្តុះបណ្តាលចំណេះដឹង និងជំនាញដល់ក្របខ័ណ្ឌមន្ត្រី បុគ្គលិករាជការ ។
- បណ្តុះបណ្តាលវិជ្ជាជីវៈក្នុងមជ្ឈមណ្ឌល/សាលាហ្វឹកហ្វឺន ដល់តំណាង/ប្រជារាស្ត្រជនបទ ដើម្បីបង្កើនមុខរបរសំរាប់ចិញ្ចឹមជីវិត ។
- រៀបចំសិក្ខាសាលា/សន្និសីទ សំរាប់បង្កើនការយល់ដឹង និងផ្លាស់ប្តូរបទពិសោធន៍ដល់មន្ត្រី បុគ្គលិករាជការ និងប្រជាជន ។
- គ្រប់គ្រងមជ្ឈមណ្ឌលឯកសារ(បណ្ណាល័យ)របស់ក្រសួង និងមជ្ឈមណ្ឌលបណ្តុះបណ្តាលបច្ចេកទេស និងវិជ្ជាជីវៈ ថ្នាក់ភូមិភាគ ។
- ស្រាវជ្រាវផ្នែកបច្ចេកវិទ្យាសមស្រប និងដកពិសោធន៍លើគំរោងសំខាន់ៗ ។
- ផលិត និងចងក្រងឯកសារបច្ចេកទេស សេដ្ឋកិច្ច ដែលបានស្រាវជ្រាវ ដើម្បីជាមូលដ្ឋានសំរាប់ធ្វើការបណ្តុះបណ្តាល និងផ្សព្វផ្សាយ ។
- រៀបចំឯកសារ និងកម្មវិធីអភិវឌ្ឍន៍ជនបទ សំរាប់ផ្សព្វផ្សាយតាមវិទ្យុ ទូរទស្សន៍ និងទស្សនាវដ្តី ដើម្បីរួមចំណែកឱ្យបានទូលំទូលាយ ក្នុងការបណ្តុះបណ្តាល អប់រំ និងឃោសនាពីខ្លឹមសារ អត្ថប្រយោជន៍ សកម្មភាព និងសមិទ្ធផលនៃការងារអភិវឌ្ឍន៍

ជនបទ សំរាប់ទាក់ទាញការចូលរួម កិច្ចសហប្រតិបត្តិការ និងការជួយឧបត្ថម្ភគាំទ្រពីសំណាក់ភ្នាក់ងារជាតិ អន្តរជាតិ ផ្នែកឯកជន ព្រមទាំងប្រជាពលរដ្ឋទូទៅ ។

- តាមដាន វាយតម្លៃការងារបំពាក់បំប៉ន និងផ្សព្វផ្សាយ ។

## ជំពូក ៥

## អគ្គនាយកដ្ឋានបច្ចេកទេស

**មាត្រា ១១:** អគ្គនាយកដ្ឋានបច្ចេកទេស ទទួលបន្ទុកធ្វើទំនាក់ទំនង សំរបសំរួល និងគ្រប់គ្រងកម្មវិធីផ្លូវលំជនបទ ផ្គត់ផ្គង់ទឹកជនបទ ថែទាំសុខភាពបឋម អភិវឌ្ឍសហគមន៍ និងអភិវឌ្ឍសេដ្ឋកិច្ចជនបទ ។ អគ្គនាយកដ្ឋានដឹកនាំដោយអគ្គនាយកមួយរូប ដែលអាចអមដោយអគ្គនាយករង ជាជំនួយការតាមការចាំបាច់ ។ អគ្គនាយកដ្ឋាននេះមាននាយកដ្ឋានចំណុះចំនួន ៤ ដូចតទៅ:

- នាយកដ្ឋានផ្គត់ផ្គង់ទឹកជនបទ
- នាយកដ្ឋានថែទាំសុខភាពជនបទ
- នាយកដ្ឋានអភិវឌ្ឍន៍សហគមន៍
- នាយកដ្ឋានអភិវឌ្ឍន៍សេដ្ឋកិច្ចជនបទ ។

**មាត្រា ១២:** នាយកដ្ឋានផ្គត់ផ្គង់ទឹកជនបទទទួលបន្ទុក:

- រៀបចំ លើកផែនការស្តារ និងអភិវឌ្ឍប្រព័ន្ធស្រោចស្រពខ្នាតតូចថ្នាក់គ្រួសារ ភូមិ ឃុំ ប្រព័ន្ធថាមពលតូចៗ ព្រមទាំងកម្មវិធីផ្គត់ផ្គង់ទឹកស្អាត និងទឹកប្រើប្រាស់ សំរាប់រយៈពេលខ្លី មធ្យម និងយូរអង្វែង ។
- សិក្សា ស្រាវជ្រាវ លើកគំរោង និងជួសជុល សាងសង់ប្រព័ន្ធស្រោចស្រពខ្នាតតូចថ្នាក់គ្រួសារ ភូមិ ឃុំ ប្រព័ន្ធថាមពលតូចៗ ព្រមទាំងកម្មវិធីផ្គត់ផ្គង់ទឹកស្អាត និងទឹកប្រើប្រាស់ ដោយសហការជាមួយស្ថាប័នពាក់ព័ន្ធ ។
- ត្រួតពិនិត្យគុណភាពទឹកអណ្តូងដែលបានជីករួច មុននឹងដាក់ជូនប្រជាពលរដ្ឋមូលដ្ឋានប្រើប្រាស់ ។
- រៀបចំបែបបទដែលពាក់ព័ន្ធនឹងកិច្ចដំណើរការ និងថែទាំដោយប្រជាជន នូវទឹកស្អាត ទឹកប្រើប្រាស់ និងទឹកស្រោចស្រពខ្នាតតូច ព្រមទាំងការរៀបចំសមាគម ឬក្រុមអ្នកប្រើប្រាស់ទឹកនៅជនបទ ។



៥

**មាត្រា ១៣:** នាយកដ្ឋានថែទាំសុខភាពជនបទទទួលបន្ទុក:

- រៀបចំ លើកផែនការថែទាំសុខភាពបឋម នៅតាមសហគមន៍ជនបទ សំរាប់រយៈពេលខ្លី មធ្យម និងយូរអង្វែង ។
- បណ្តុះបណ្តាលចំណេះដឹង និងជំនាញផ្នែកថែទាំសុខភាពបឋម និងអនាម័យដល់មន្ត្រីរាជការអភិវឌ្ឍន៍ជនបទ និងភ្នាក់ងារសុខភាពស្ម័គ្រចិត្តតាមភូមិ ។
- អប់រំសហគមន៍អំពីការថែទាំសុខភាពបឋម ដែលជាអាទិ៍រួមមាន ការអប់រំអំពីអាហារូបត្ថម ការគាំពារសុខភាពស្ត្រី ការលូតលាស់របស់កុមារ ការថែទាំសុខភាពផ្លូវចិត្ត និងការការពារជម្ងឺផ្សេងៗ ។
- រៀបចំអនាម័យបរិស្ថានក្នុងភូមិ ដោយជួយឧបត្ថម្ភ និងបំផុសប្រជាជនចូលរួម ក្នុងការសាងសង់បង្គន់អនាម័យតាមគ្រួសារ និងទីសាធារណៈ ព្រមទាំងអប់រំអ្នកភូមិឱ្យសំអាតលំនៅឋាន និងប្រើប្រាស់ទឹកស្អាត ។

**មាត្រា ១៤:** នាយកដ្ឋានអភិវឌ្ឍន៍សហគមន៍ទទួលបន្ទុក:

- រៀបចំ លើកផែនការអភិវឌ្ឍសហគមន៍ សំរាប់រយៈពេលខ្លី មធ្យម និងយូរអង្វែង ។
- សិក្សា ស្រាវជ្រាវ លើកគំរោង និងជួសជុល សាងសង់សំណង់ហេដ្ឋារចនាសម្ព័ន្ធជនបទ ដូចជាផ្លូវលំ ស្ពាន សាលារៀន មណ្ឌលសុខភាព ភូមិអភិវឌ្ឍន៍ ។ល។ តាមផែនការដែលបានដាក់ចុះ ដោយសហការជាមួយស្ថាប័នពាក់ព័ន្ធ ។
- សាងសង់ និងគ្រប់គ្រង មជ្ឈមណ្ឌលអភិវឌ្ឍន៍សហគមន៍ ។
- ជំរុញ និងលើកទឹកចិត្តប្រជាជនឱ្យបង្កើនផលិតកម្មស្បៀង ដើម្បីផ្គត់ផ្គង់គ្រួសារ និងទីផ្សារ ។
- បញ្ជូនភ្នាក់ងារអភិវឌ្ឍន៍សហគមន៍ ចុះទៅតាមមូលដ្ឋានជនបទ ដើម្បីធ្វើការអប់រំក្រៅប្រព័ន្ធជូនប្រជាជន អំពីអក្ខរកម្ម ការការពារបរិស្ថាន និងធនធានធម្មជាតិ ព្រមទាំងការលើកទឹកចិត្តឱ្យដាំព្រៃឈើឡើងវិញ ការថែរក្សាប្រពៃណី វប្បធម៌ និងសីលធម៌ក្នុងការរស់នៅ សិទ្ធិប្រជាពលរដ្ឋ លទ្ធិប្រជាធិបតេយ្យ បច្ចេកវិទ្យាសមស្របក្នុងដំណើរការផលិតកម្ម ការការពារគ្រោះថ្នាក់មីន ។ល។
- ខិតខំជួយដោះស្រាយដល់ជនមាតុភូមិនិវត្តន៍ និងជនផ្លាស់ប្តូរទីលំនៅ ។



៦

- រៀបចំបែបបទដែលពាក់ព័ន្ធនឹងកិច្ចដំណើរការ និងថែទាំដោយប្រជាជន នូវហេដ្ឋារចនាសម្ព័ន្ធជនបទ ដើម្បីធានាឱ្យមានការអភិវឌ្ឍន៍ជនបទ ប្រកបដោយចីរភាព ។
- រៀបចំបែបបទក្នុងការបង្កើត ពង្រីក និងពង្រឹងរចនាសម្ព័ន្ធអភិវឌ្ឍន៍ជនបទ ជាពិសេស គណៈកម្មការអភិវឌ្ឍន៍ភូមិ-ឃុំ ។

**មាត្រា ១៥:** នាយកដ្ឋានអភិវឌ្ឍន៍សេដ្ឋកិច្ចជនបទទទួលបន្ទុក:

- រៀបចំ លើកផែនការអភិវឌ្ឍន៍សេដ្ឋកិច្ចជនបទ សំរាប់រយៈពេលខ្លី មធ្យម និងយូរអង្វែង ។
- រៀបចំគោលការណ៍ និងបំផុសប្រជាជនចូលរួម ក្នុងការកសាងធនាគារភូមិ ធនាគារស្រូវ ធនាគារសត្វ ធនាគារសម្ភារៈកសិកម្ម ។
- រៀបចំបែបបទដែលពាក់ព័ន្ធនឹងការផ្តល់ទុន ជូនប្រជារាស្ត្រខ្លី ការចងក្រងសមាគមឥណទានផ្សេងៗ ។
- លើកទឹកចិត្តប្រជារាស្ត្រជនបទ អំពីការងារសន្សំប្រាក់ តាមរយៈការផ្សព្វផ្សាយ ការរៀបចំក្រុម គណៈកម្មការសន្សំប្រាក់ ការណែនាំពីវិធានការរក្សាការពារមូលនិធិសន្សំប្រាក់ ។
- គ្រប់គ្រង ណែនាំ អំពីការរៀបចំបញ្ជីការគណនេយ្យ សំរាប់ការងារឥណទានជនបទ ។
- ជំរុញ និងលើកទឹកចិត្តប្រជាពលរដ្ឋ សមាគម ឬផ្នែកឯកជនផ្សេងៗ ក្នុងការសាងសង់សហគ្រាស និងសិប្បកម្មតូចតាចនៅជនបទ ។
- ស្វែងយល់ និងខិតខំរកទីផ្សារ ដើម្បីដោះស្រាយចរាចរផលិតផល ដោយតម្លៃសមស្រប រួមចំណែកក្នុងការលើកស្ទួយ ការជីវភាពរស់នៅរបស់ប្រជាកសិករ និងសិប្បករនៅជនបទ ។

## ជំពូក ៦
## ខុទ្ទកាល័យរដ្ឋមន្ត្រី

**មាត្រា ១៦:** ខុទ្ទកាល័យរដ្ឋមន្ត្រីទទួលបេសកកម្មទាំងឡាយ ដែលកំណត់តាមបទបញ្ញត្តិនៃអនុក្រឹត្យលេខ ២០ អនក្រ.បក ចុះថ្ងៃទី៣០ ខែមេសា ឆ្នាំ១៩៩៦ ដូចមានយោងក្នុងមូលបទខាងលើ ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅរបស់ក្រសួង និងរដ្ឋលេខាធិការដ្ឋាន ។

## ជំពូក ៧

## អង្គភាពមូលដ្ឋាន

**មាត្រា ១៧:** នៅតាមខេត្ត/ក្រុងនីមួយៗ មានមន្ទីរអភិវឌ្ឍន៍ជនបទខេត្ត/ក្រុងមួយ ដែលទទួលបន្ទុក អនុវត្ត និងសម្របសម្រួលសកម្មភាព របស់ក្រសួងអភិវឌ្ឍន៍ជនបទ ។

## ជំពូក ៨

## អង្គភាពត្រួតពិនិត្យហិរញ្ញវត្ថុ

**មាត្រា ១៨:** អង្គភាពត្រួតពិនិត្យហិរញ្ញវត្ថុ ត្រូវបានបង្កើតឡើងដោយរដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ តាមល័ក្ខខ័ណ្ឌនៃបទបញ្ជាកំណត់ក្នុងអនុក្រឹត្យលេខ ៨១ ចុះថ្ងៃទី១៦ ខែវិច្ឆិកា ឆ្នាំ១៩៩៩ ស្តីពីការបង្កើតស្ថាប័នត្រួតពិនិត្យហិរញ្ញវត្ថុ លើការចំណាយថវិកាក្នុងបណ្តាក្រសួង ។

## ជំពូក ៩

## អវសានប្បញ្ញត្តិ

**មាត្រា ១៩:** ការរៀបចំ និងការប្រព្រឹត្តទៅរបស់ក្រសួងនៅរដ្ឋបាលកណ្តាល ចាប់ពីថ្នាក់ក្រោមនាយកដ្ឋានចុះ ត្រូវកំណត់ដោយប្រកាសរបស់រដ្ឋមន្ត្រីក្រសួងអភិវឌ្ឍន៍ជនបទ ។

**មាត្រា ២០:** ភារកិច្ចទាំងឡាយណា ដែលពាក់ព័ន្ធនឹងសមត្ថកិច្ចរបស់ស្ថាប័នដទៃ ប្រធានស្ថាប័ន នៃស្ថាប័នដទៃទាំងនោះ និងរដ្ឋមន្ត្រីក្រសួងអភិវឌ្ឍន៍ជនបទ ត្រូវសហការគ្នាដើម្បីបែងចែកការងារទទួលខុសត្រូវ និងអនុវត្តការងារទាំងនោះ តាមរយៈប្រកាសរួម របស់រដ្ឋមន្ត្រីក្រសួងអភិវឌ្ឍន៍ជនបទ និងប្រធានស្ថាប័នទាំងនោះ ។

**មាត្រា ២១:** បទបញ្ញត្តិទាំងឡាយណាដែលផ្ទុយនឹងអនុក្រឹត្យនេះ ត្រូវទុកជានិរាករណ៍ ។

**មាត្រា ២២:** សហរដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងអភិវឌ្ឍន៍ជនបទ រដ្ឋមន្ត្រី និងរដ្ឋលេខាធិការទាំងអស់ដែលមានការពាក់ព័ន្ធ ត្រូវអនុវត្តអនុក្រឹត្យនេះតាមភារកិច្ចរៀងៗខ្លួន ។

**មាត្រា ២៣:** អនុក្រឹត្យនេះចូលជាធរមាន ចាប់ពីថ្ងៃចុះហត្ថលេខាតទៅ ។

រាជធានីភ្នំពេញ ថ្ងៃទី០១ ខែ ៦ ឆ្នាំ ១៩៩៧

**នាយករដ្ឋមន្ត្រីទី១**　　**នាយករដ្ឋមន្ត្រីទី២**

**អ៊ុង ហួត**　　**ហ៊ុន សែន**

**បានជំរាបជូន:**

- ឯកឧត្តមនាយករដ្ឋមន្ត្រីទី ១
- សម្តេចនាយករដ្ឋមន្ត្រីទី ២

**ជ.រដ្ឋមន្ត្រីក្រសួងអភិវឌ្ឍន៍ជនបទ**

**រដ្ឋលេខាធិការ**

**យឹម ឆៃលី**

**កន្លែងទទួល:**

- ខុទ្ទកាល័យព្រះមហាក្សត្រ
- អគ្គលេខាធិការដ្ឋានរដ្ឋសភា
- ខុទ្ទកាល័យនាយករដ្ឋមន្ត្រីទី១
- ខុទ្ទកាល័យសម្តេចនាយករដ្ឋមន្ត្រីទី២
- គ្រប់ក្រសួង ស្ថាប័នកណ្តាល
- គ្រប់សាលាខេត្ត-ក្រុង
- ដូចមាត្រា២២
- ឯកសារ-កាលប្បវត្តិ

ឧបសម្ព័ន្ធនៃអនុក្រឹត្យលេខ : ៧៨ អនក្រ-បក
ចុះថ្ងៃទី០១ ខែ ៩ ឆ្នាំ ១៩៩៧

# អង្គការលេខរបស់ក្រសួងអភិវឌ្ឍន៍ជនបទ

